ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍បាត់ដំបង**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងលេខ: ២៨៩

ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

**សាលដីកាលេខ: ៤៦៦(ខ)**

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

17-10.22

សុំ ២០ច្បាប់

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះ ដូចខាងក្រោម ៖

១.លោក [redacted] ជាប្រធានក្រុមប្រឹក្សា

២.ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

៣.លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងឧទ្ធរណ៍លេខ ០២២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់លោកព្រះរាជអាជ្ញារង [redacted] ហ៊ួរ ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២០"ឃ"/៧៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] សារុធ ហ្ហ តឿ ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្នភូមិស្លែងពណ៌ ឃុំត្រពាំងត្រាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ (ទោសពីមុនគ្មាន) ។ (ឃុំខ្លួន)

ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ០០៨ ដបឃ/២២/១៨.០១.២២។

**ជាប់ចោទពីបទ:** អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្លែងពណ៌ ឃុំត្រពាំងត្រាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃ



Scanned with CamScanner

ទី១៥ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ (ជាអ្នកប្តឹងឧទ្ធរណ៍)

**ដើមបណ្តឹងរដ្ឋប្បវេណី**

១-ឈ្មោះ [redacted] សុចុន ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិស្លែងពណ៌ ឃុំត្រពាំងក្រាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**អំពីអង្គហេតុ ៖**

-កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ ស្ថិតនៅក្នុងភូមិស្លែងពណ៌ ឃុំត្រពាំងក្រាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានករណីហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាស ដោយឃាត់ខ្លួនជនជាប់សង្ស័យឈ្មោះ [redacted] សាវុធ ហៅ តឿ ភេទប្រុស អាយុ ៣៨ឆ្នាំ។ តាមចម្លើយរបស់ជនជាប់សង្ស័យឈ្មោះ [redacted] សាវុធ ហៅ តឿ បានសារភាពថា ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ ខ្លួនបានទៅផឹកស៊ីពីម៉ោង ១១ថ្ងៃត្រង់ នៅផ្ទះឪពុកម្តាយរបស់ខ្លួនដល់ម៉ោង ០៨យប់ ទើបត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ។ ដោយសារខ្លួនមានសភាពស្រវឹងជោគជាំផង ខ្លួនក៏បានឡើងទៅលើផ្ទះរួចចូលដេកទៅ។ ដោយឡែកប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] សុចុន បានទៅចូលរួមពិធីខួបកំណើតខាងបងប្អូននៅផ្ទះម្តាយក្មេក (ម្តាយបង្កើតខ្លួន) ខ្លួនមិនបានដឹងថា ប្រពន្ធត្រឡប់មកផ្ទះវិញពីពេលណានោះទេ រហូតដល់ម៉ោងប្រហែលជា២ រៀបភ្លឺ បានខ្លួនដឹងថា ប្រពន្ធបានមកដល់ផ្ទះ ពេលនោះឈ្មោះ [redacted] សុចុន បានសួរខ្លួនថា ថ្ងៃមិញខ្លួនទៅណា? ខ្លួនក៏ឆ្លើយថា ទៅគស់យ៉ាបផ្ទះឱ្យគេ ហើយឈ្មោះ [redacted] សុចុន ក៏សួរបន្តទៀតថា ហើយគេឱ្យលុយនៅ? ខ្លួនឆ្លើយថា ធ្វើឱ្យគេមិនទាន់ហើយអ្នកណាគេបើកលុយឱ្យ។ ឈ្មោះ [redacted] សុចុន រអ៊ូរទៀតថា ឥលូវរវល់តែធ្វើអីនៅក្រាំក្រែងនៅនឹង មិនទៅកន្លែងការងារនៅខេត្តកំពតវិញទេឬ? ហើយខ្លួនក៏បានឆ្លើយថាមិនបានទៅទេព្រោះខ្លួនជាប់កាន់អាត្រាក់ទ័រឱ្យគេនៅនឹង។ ប្រពន្ធរបស់ខ្លួននៅតែរអ៊ូរដាក់ខ្លួនដដែលរហូតដល់ខ្លួនខឹង ក៏ស្ទុះទៅយកដបសាំងដែលទុកជាប់នឹងជញ្ជាំងផ្ទះក្បែរជណ្តើរចំនួន ០២លីត្រ ដែលខ្លួនបានទិញទុកពីល្ងាចសម្រាប់ចាក់ម៉ាស៊ីនដោំង ជៀកឈើ។ ខ្លួនបាននិយាយទៅប្រពន្ធថា ខ្លួននឹងយកសាំងដុតខ្លួនឯង តែតាមចម្លើយរបស់ឈ្មោះ [redacted] សុចុន នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា ប្តីរបស់ខ្លួនឈ្មោះ [redacted] សាវុធ បានកាន់ដបសាំងចំនួន ០១ដប ចំណុះ ០១លីត្រ ចាក់ទៅលើក្តារជុំវិញកន្លែងដែលខ្លួនឈរ ទើបខ្លួនមកចាប់ដៃពីក្រោយ ក្នុងគោលបំណងរារាំងមិនឱ្យដុត តែយកមិនបាន ដកសាំងក៏បានស្រក់ពប់ពេញក្តារលើផ្ទះ និងកំពប់ប៉ះចំជើងខ្លួន។ បន្ទាប់មកទៀតឈ្មោះ [redacted] សាវុធ ក៏បានយកដែកកេះមកបញ្ឆេះដុតខ្លួនបណ្តាលឱ្យរលាកជើងពីក្រោយទាំងពីរ និងរលាកដៃខាងស្តាំ។ តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនរបស់ឈ្មោះ [redacted] សាវុធ ហៅ តឿ ជាលទ្ធផលវិជ្ជមាន។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២០"ឃ"/៧៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលបានសម្រេចៈ

១-ផ្តន្ទាទោសឈ្មោះ [redacted]ាវុធ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ។

ពីបទៈ អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

២-ចំពោះវត្ថុតាងដកហូតបានរួមមាន៖



Scanned with CamScanner

-ប្រេងសាំងចំនួន ០១លីត្រ ច្រកក្នុងដបថ្មកែវពណ៌សថ្លា រាងបួនជ្រុងទ្រវែង ចំណុះ ០១លីត្រ និងពូថៅចំនួន ០១ដើម ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

-សំបកដបសាំងចំនួន ០១ថ្មកែវ ពណ៌សថ្លា រាងបួនជ្រុងទ្រវែង ចំណុះ ០១លីត្រ និងធុងបែកចំនួន ០១ ត្រូវរឹបអូសបំផ្លាញចោល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០២២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់លោកព្រះរាជអាជ្ញារង [redacted] ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២០"ឃ"/៧៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ប្តឹងត្រង់ចំណុចទី១ នៃសេចក្តីសម្រេច។

-បានឃើញ របាយការណ៍របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍។

-ជនជាប់ចោទឈ្មោះ [redacted] សាវុធ ហ៊ា តឿ បានឆ្លើយថា: ខ្ញុំបាទបានទទួលស្គាល់កំហុសរបស់ខ្លួនទាំងអស់ហើយ ពេលនឹងខ្ញុំមិនបានយកចាក់សាំងដុតប្រពន្ធទេ ដោយគ្រាន់តែចាក់ដុតផ្ទះតែប៉ុណ្ណោះ ហើយចំពោះការផ្តន្ទាទោសខ្ញុំ ០២ឆ្នាំ ក៏ខ្ញុំព្រមទទួលយកដែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចុន បានឆ្លើយថា: ខ្ញុំធ្លាប់ឈ្លោះគ្នាដែរពីមុន តែមិនដែលឈ្លោះខ្លាំងដូចថ្ងៃកើតហេតុទេ ពេលនោះប្តីរបស់ខ្លួនឈ្មោះ [redacted] សាវុធ បានកាន់ដបសាំងចំនួន ០១ដប ចំណុះ ០១លីត្រ ចាក់ទៅលើក្តារជុំវិញកន្លែងដែលខ្លួនឈរ ទើបខ្លួនមកចាប់ដៃពីក្រោយ ក្នុងគោលបំណងរារាំងមិនឱ្យដុត តែយកមិនបានដកសាំងក៏បានគ្រវីកំពប់ពេញក្តារលើផ្ទះ និងកំពប់ប៉ះចំជើងខ្លួន។ ហើយរាល់ថ្ងៃនាងខ្ញុំបានដាក់ពាក្យលែងលះគ្នាហើយ ដោយមានកូនពីរនាក់នៅជាមួយនឹងខ្ញុំ។

-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សា និងចៅក្រមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] សាវុធ ហ តឿ បានធ្វើការសំណូមពរចុងក្រោយថា៖ ខ្ញុំមានការសោកស្តាយនៅកំហុសរបស់ខ្ញុំ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

១-យល់ឃើញថា បណ្តឹងឧទ្ធរណ៍លេខ ០២២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់លោកព្រះរាជអាជ្ញារង [redacted] ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២០"ឃ"/៧៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចលើកយកបណ្តឹងនេះមកជំនុំជម្រះបានតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៧៣, ៣៧៤, ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

២-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនាពេលសវនាការថាខ្ញុំបាទបានទទួលស្គាល់កំហុសរបស់ខ្លួនទាំងអស់ហើយ ពេលនឹងខ្ញុំមិនបានយកចាក់សាំងដុតប្រពន្ធទេដោយគ្រាន់តែចាក់ដុតផ្ទះតែប៉ុណ្ណោះ ហើយចំពោះការផ្តន្ទាទោសខ្ញុំ ០២ឆ្នាំ ក៏ខ្ញុំព្រមទទួលយកដែរ។ ក៏ប៉ុន្តែបណ្តឹងខាងលើនេះបានធ្វើឡើងដោយតំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានលើកឡើងនូវពីរចំណុចក្នុងសារណារបស់ខ្លួន ទីមួយថាការដាក់ទោស ០២ឆ្នាំ មិនធួនល្មមទៅនឹងអំពើរបស់ជនជាប់ចោទ និងទីពីរថាអំពើរបស់ជនជាប់ចោទមានចរិតសាហាវ នោះក្រុមប្រឹក្សាជំនុំជម្រះមិនអាចពិចារណាបាននោះទេ ព្រោះថាជនជាប់ចោទបានទទួលស្គាល់កំហុសហើយ ហើយការដែលសាលាដំបូងផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន២ឆ្នាំនោះបានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ និងសមស្របទៅនឹងអំពើ ព្រមទាំងព្យសនកម្មដែលបានកើតឡើងហើយដោយអនុលោមតាមស្មារតីមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌហើយ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងថា ស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សា និងចៅក្រមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។ ចំណុចនេះ ក្រុមប្រឹក្សាជំនុំជម្រះអាចពិចារណាបានដូចទៅនឹងសម្អាងហេតុខាងលើ។

៤-យល់ឃើញថា ខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌលេខ ២០ឃ/៧៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ។

**ហេតុដូច្នេះ**

**សម្រេច**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ០២២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់លោកព្រះរាជអាជ្ញា [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយទាស់ទៅនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០ឃ/៧៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះនាសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] | [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

បាត់ដំបង ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner